


# ភាពស្របគ្នានៃមេរៀនថ្នាក់គួ

*កម្រិត ប្រភេទ និងការជាប់ទាក់ទងគ្នាសម្រាប់គោលនយោបាយ និងការគ្រប់គ្រងសាលារៀន*

អង្គការ ជីវិតនៅកម្ពុជា
THIS LIFE CAMBODIA
COMMUNITY RESEARCH AND CONSULTANCY

UNESCO
United Nations Educational, Scientific and Cultural Organization

uniTwin
UNESCO Chair in Comparative Education
The University of Hong Kong

រក្សាសិទ្ធិ©ដោយអង្គការជីវិតនៅកម្ពុជា ខែកក្កដា ឆ្នាំ២០១៦

រាល់ការផលិតរបាយការណ៍នេះឡើងវិញ ដោយមានការបញ្ជាក់ច្បាស់លាស់ អំពីប្រភព សម្រាប់គោលបំណងដែលមិនរកប្រាក់ចំណូលត្រូវបានអនុញ្ញាត។ចំពោះការថតចម្លងនៅក្នុងកាលៈទេសៈ ទាំងអស់ឬការប្រើប្រាស់ឡើងវិញ។ក្នុងការបោះពុម្ពផ្សាយផ្សេងៗទៀត ការបកប្រែ ឬកែសម្រួលយកមកប្រើប្រាស់ ត្រូវតែប្រឹក្សាជាមួយអង្គការជីវិតនៅកម្ពុជា។ របាយការណ៍នេះ ដកស្រង់ចេញពីព័ត៌មាន យោបល់ និង ឯកសារដែលមានស្រាប់របស់បុគ្គល និងអង្គការផ្សេងៗជាច្រើន។

អង្គការជីវិតនៅកម្ពុជាមិនទទួលខុសត្រូវចំពោះភាពត្រឹមត្រូវ ឬភាពពេញលេញនៃសម្ភារៈភ្ជាប់ណាមួយដែល មាននៅក្នុងរបាយការណ៍នេះទេ។ ជាងនេះទៅទៀត អង្គការជីវិតនៅកម្ពុជាក៏មិនទទួលស្គាល់ បុគ្គលណាម្នាក់ដែលមិនគោរពតាមព័ត៌មាន ដែលបានបង្ហាញជូនក្នុងការបោះពុម្ពផ្សាយនេះ។

អង្គការជីវិតនៅកម្ពុជា ផ្ទះលេខ ៣១៣ ក្រុមទី៩ ភូមិសាលាកន្សែង សង្កាត់ស្វាយដង្គំ ក្រុងនិងខេត្តសៀមរាប ព្រះរាជាណាចក្រកម្ពុជា គេហទំព័រ www.thislifecambodia.org

# អំពីការសិក្សាស្រាវជ្រាវនេះ

មជ្ឈមណ្ឌលសិក្សាស្រាវជ្រាវប្រៀបធៀបការអប់រំ នៃសាកលវិទ្យាល័យហុងកុងដែលទទួលធ្វើដោយក្រុមអ្នកសិក្សាស្រាវជ្រាវអន្តរជាតិមួយក្រុម លើប្រធានបទស្រមោលនៃការអប់រំដឹកនាំដោយសាស្ត្រាចារ្យ Mark Bray បន្ថែមលើប្រធានបទប្រទេសកម្ពុជា សមាជិកក្រុមបានជាពិសេសលើស្រមោលនៃការអប់រំក្នុងប្រទេស បង់ក្លាដេស ចិន ចចជៀ ហុងកុង និង ឥណ្ឌា។ ការបោះពុម្ពអាចរកបានពី CERC (http://cerc.edu.hku.hk) រួមមាន:

Bray, Mark & Lykins, Chad (2012): Shadow Education: Private Tutoring and its Implications for Policy Makers in Asia. Manila: Asian Development Bank, and Hong Kong: Comparative Education Research Centre, សាកលវិទ្យាល័យហុងកុង, 98 pp.

Bray, Mark & Kwo, Ora (2014): Regulating Private Tutoring for Public Good: Policy Options for Supplementary Education in Asia. Hong Kong: Comparative Education Research Centre, សាកលវិទ្យាល័យហុងកុង, and Bangkok: UNESCO Asia and Pacific Regional Bureau for Education, 93 pp.

Bray, Mark; Kwo, Ora & Jokić, Boris (eds.) (2015): Researching Private Supplementary Tutoring: Methodological Lessons from Diverse Cultures. Hong Kong: Comparative Education Research Centre, សាកលវិទ្យាល័យហុងកុង, and Dordrecht: Springer, 292 pp.

កម្មវិធីសិក្សាស្រាវជ្រាវសហគមន៍ និង ប្រឹក្សាបច្ចេកទេស គឺជាគម្រោងរបស់អង្គការជីវិតនៅកម្ពុជា។ អង្គការជីវិតនៅកម្ពុជា ជាអង្គការមិនរកកម្រៃ មិនមែនរដ្ឋាភិបាល ជាអង្គការអភិវឌ្ឍន៍សហគមន៍ដែលមានមូលដ្ឋានក្នុងខេត្តសៀមរាប។ កម្មវិធីសិក្សាស្រាវជ្រាវសហគមន៍ និងប្រឹក្សាបច្ចេកទេស គឺទទួលបានការគាំទ្រដោយមូលនិធិសប្បុរសជន ការបរិច្ចាគឯកជន អង្គការជំនួយផ្សេងៗ តាមការផ្តល់សេវាស្រាវជ្រាវ ប្រឹក្សាបច្ចេកទេស និងវាយតម្លៃ។ ការងាររបស់កម្មវិធីសិក្សាស្រាវជ្រាវសហគមន៍ និង ប្រឹក្សាបច្ចេកទេស (CRCP) នេះគឺផ្តល់នូវយន្តការសម្រាប់សំលេងសហគមន៍ក្រីក្រឱ្យបានឮ។ ស្របជាមួយនឹងបេសកកម្មរបស់អង្គការជីវិតនៅកម្ពុជា គឺ ស្តាប់ ចូលរួមចំណែក និង ស្វែងរកមតិគាំទ្រស្របជាមួយសហគមន៍ CRCP បកស្រាយសំលេងនានា ទៅជាចំណេះដឹងថ្មីមួយ បន្ទាប់មកគេអាចប្រើប្រាស់វាជាឧបករណ៍មួយ សម្រាប់ស្វែងរកមតិគាំទ្រឱ្យមានការផ្លាស់ប្តូរជាវិជ្ជមាន។

**អាគតដ្ឋានៈ**

Bray, Mark (2016): Parallel Private Lessons: Scale, Nature and Implications for Policy and School Management. Siem Reap: This Life Cambodia, and Hong Kong: Comparative Education Research Centre, សាកលវិទ្យាល័យហុងកុង.

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងៈ**

អង្គការជីវិតនៅកម្ពុជា (TLC), contact@thislifecambodia.org និង/ឬ

សាស្ត្រាចារ្យ Mark Bray, University of Hong Kong, mbray@hku.hk

# ភាពស្របគ្នានៃមេរៀនថ្នាក់គួ

## កម្រិត ប្រភេទ និងការជាប់ទាក់ទងគ្នាសម្រាប់គោលនយោបាយ និងការគ្រប់គ្រងសាលារៀន

សកលវិទ្យាល័យហុងកុង (HKU) បានរៀបចំគម្រោងស្រាវជ្រាវជាមួយនឹងអង្គការជីវិតនៅកម្ពុជា (TLC) ដើម្បីស្វែងរកកម្រិត និងប្រភេទលើភាពស្របគ្នានៃមេរៀនថ្នាក់គួដែលបានធ្វើជាមួយសិស្សកម្រិតអនុវិទ្យាល័យ។ ដោយផ្តោតលើការរៀនមេរៀនថ្នាក់គួ ដែលស្របគ្នាទៅនឹងការសិក្សារបស់សាលារដ្ឋ ក្នុងនោះជាធម្មតាគ្រូបង្រៀនសិស្សនៅក្នុងថ្នាក់រដ្ឋដដែល ហើយបង្រៀនគួដល់សិស្សមកពីថ្នាក់រដ្ឋដដែលនៅលើបរិវេណតែមួយ។ ការស្រាវជ្រាវនេះ គឺបានផ្តោតលើសំណាកសាលារៀននៅក្នុងខេត្តសៀមរាប។ របាយការណ៍នេះ គឺបង្ហាញពីការរកឃើញនូវគន្លឹះសំខាន់ៗនៃការជាប់ទាក់ទងគ្នា សម្រាប់អ្នកបង្កើតគោលនយោបាយនិងអ្នកគ្រប់គ្រងសាលារៀន។ ទោះបីជាការរកឃើញ បានធ្វើនៅក្នុងខេត្តសៀមរាបតែមួយក៏ដោយ ប៉ុន្តែវាក៏មានការជាប់ពាក់ព័ន្ធទៅនឹងខេត្តដទៃផ្សេងទៀតនៅក្នុងប្រទេសផងដែរ។

របាយការណ៍នេះ គឺមានការពន្យល់ពីហេតុផលលើចំណុចស្របគ្នាក្នុងការស្រាវជ្រាវ និងបញ្ហាដែលលើកឡើង ចំពោះភាពស្របគ្នានៃមេរៀនថ្នាក់គួ។ បន្ទាប់មក គឺពន្យល់ពីការជ្រើសរើសសំណាកសាលារៀន សិស្ស គ្រូបង្រៀន និងយុទ្ធសាស្ត្រតាមរយៈទិន្នន័យដែលប្រមូលបាន។ ផ្នែកបន្តបន្ទាប់ បង្ហាញពីការរកឃើញបែបបរិមាណ និងគុណភាព ហើយផ្នែកចុងក្រោយផ្តល់នូវអនុសាសន៍សម្រាប់អ្នកបង្កើតគោលនយោបាយ និងអ្នកគ្រប់គ្រងសាលារៀន។

## ១. បញ្ហា

ភាពស្របគ្នានៃមេរៀនថ្នាក់គួ ស្ថិតក្នុងទម្រង់នៃការអប់រំកម្ពុជាយ៉ាងហោចណាស់ នាដើមទសវត្សរ៍ឆ្នាំ១៩៩០។ អ្នកគ្រប់គ្នាបានដឹងពីបរិបទក្នុងសម័យកាលនោះ ប៉ុន្តែជាទូទៅពួកគេ គឺមិនបានយកចិត្តទុកដាក់ក្នុងការពិភាក្សាលើគុណភាព និងការគ្រប់គ្រងនៅក្នុងសាលារដ្ឋនោះទេ។ របាយការណ៍នេះអះអាងថា ភាពស្របគ្នានៃមេរៀនគួ គឺវាចាំបាច់ណាស់សម្រាប់ចូលរៀនបន្ថែមលើអ្វីដែលពួកគេទទួលបានកន្លងទៅ។

មានការសិក្សាមួយចំនួននាពេលកន្លងមក ពីភាពស្របគ្នានៃមេរៀនថ្នាក់គួ នៅក្នុងប្រទេសកម្ពុជា គឺបានផ្តោតលើកម្រិត និងការជាប់ទាក់ទងគ្នាលើថវិកាចំណាយក្នុងគ្រួសារ (ឧទាហរណ៍ Bray ឆ្នាំ១៩៩៩; Bray និង Bunly ឆ្នាំ២០០៥ ភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល ឆ្នាំ២០០៧; អង្គការសហប្រជាជាតិឆ្នាំ ២០១៤)។ មានការពិចារណាផ្សេងទៀត ជាមួយអ្នកគ្រប់គ្រងសាលារដ្ឋ និងការជាប់ទាក់ទងលើការងារគ្រូបង្រៀន និងកម្រិតដទៃជាច្រើនទៀត (ឧទាហរណ៍ Dawson ឆ្នាំ២០០០; Brehm, Silova និង Tuot ឆ្នាំ២០១២)។

ភស្តុតាងជាច្រើនដែលមានស្រាប់លើការរៀបរាប់ទាំងនោះ កំពុងលេចចេញជាការបង្ហាញសម្រាប់ការស្រាវជ្រាវ ក្នុងនោះរួមមានដូចខាងក្រោម:

***គ្មានវិសមភាពសង្គម:*** នៅពេលបង់ថ្លៃសាលាសម្រាប់ការចូលរៀនបន្ថែម កុមារដែលពុំមានលទ្ធភាពបង់ថ្លៃរៀនទាំងនោះ គឺមិនត្រូវបានរាប់បញ្ចូលឡើយ។ ស្ថានភាពនៃការមិនយោគយល់បែបនេះ នឹងធ្វើឱ្យវិសមភាពសង្គមកើនឡើង និងជាពិសេសបញ្ហានៅពេលមានការបន្ថែមថ្នាក់រៀន ក្នុងករណីចាំបាច់សម្រាប់បញ្ចប់កម្មវិធីសិក្សាទាំងមូល។

***ចំណូលរបស់គ្រូបង្រៀន:*** ថ្នាក់រៀនគួភាគច្រើន គឺបានបង្រៀនជាទៀងទាត់ចំពោះគ្រូបង្រៀនដែលមានប្រាក់ខែទាប។ ចំណូលបានពីថ្នាក់រៀនគួ គឺផ្គត់ផ្គង់លើប្រាក់ខែរបស់គ្រូបង្រៀនបន្ថែម និងដើម្បីរក្សាគ្រូបង្រៀនស្ថិតក្នុងក្រមវិជ្ជាជីវៈ។

***ផលអវិជ្ជមានលើសាលារដ្ឋ:*** នៅពេលសិស្សមួយចំនួនទទួលបានមេរៀនបន្ថែម ប៉ុន្តែសិស្ស ដទៃទៀតពុំបានទទួល គឺភាពខុសគ្នាមានការកើនឡើងនៅក្នុងសាលារដ្ឋ។ ដូច្នេះ គ្រូដែលផ្តល់ មេរៀនគួច្រើនជាង នៅក្នុងការបង្រៀនរបស់ពួកគេ វាអាចធ្លាក់ចុះសម្រាប់ការខិតខំប្រឹងប្រែងរបស់គ្រូក្នុងការផ្តល់មេរៀនក្នុងសាលារដ្ឋ ដោយផ្តោតតែទៅលើមេរៀនថ្នាក់គួ។ ហើយចំពោះគ្រូបង្រៀនណា ដែលចង់បង្កើនប្រាក់ចំណូលរបស់ខ្លួនឱ្យបានខ្ពស់នោះ (ជាពិសេសគឺពេលប្រលងថ្នាក់ជាតិ) ដែលនេះគឺជាការរួមចំណែកពីការធ្វេសប្រហែសរបស់ថ្នាក់ក្រោម មិនមែនមានតែប្រទេសកម្ពុជាទេ មានការប្រឈមនឹងបញ្ហាទាំងនេះ ដែលត្រូវបានកំណត់បង្ហាញ ដោយក្រុមការងារ HKU និងអ្នកផ្សេងទៀត នៅតាមបណ្តាប្រទេសជាច្រើន (ឧទាហរណ៍ Bray & Lykins ឆ្នាំ២០១២ Jokić ឆ្នាំ២០១៣ Bray & Kwo ឆ្នាំ២០១៤)។ ប្រទេសកម្ពុជាមានឱកាសទាំងការរួមចំណែក និងការរៀនសូត្រលើការវិភាគពីប្រទេសដទៃផ្សេងទៀត។

## ២. សំណាក និងវិធីសាស្ត្រ

ទិន្នន័យនៅក្នុងរបាយការណ៍នេះ គឺបានប្រមូលពីសាលារៀនចំនួន ៦ នៅក្នុងខេត្តសៀមរាប។ សាលារៀនដែលត្រូវបានជ្រើសរើស ដើម្បីបង្ហាញពីភាពខុសគ្នា ដោយកំណត់ទៅលើស្ថាប័នទាំងប្រាំមួយ ដែលបានជួយក្នុងការធានាពីកម្រិតយលដឹង ខណៈពេលមានការកំណត់នូវភាពខុសគ្នានៅក្នុងខេត្ត។ ក្នុងចំណោមសាលារៀនទាំងប្រាំមួយ គឺមានអនុវិទ្យាល័យចំនួនបីដែលកំពុងបង្រៀនចាប់ពីថ្នាក់ទី៧ដល់ថ្នាក់ទី៩ និងមានវិទ្យាល័យចំនួនបីដែលបង្រៀនចាប់ពីថ្នាក់ទី៧ដល់ថ្នាក់ទី១២។ មានសាលារៀនចំនួន៣ស្ថិតនៅក្នុងទីក្រុង ឬទីប្រជុំជន និងមានសាលារៀនចំនួន៣ទៀតនៅជនបទ ឬទីដាច់ស្រយាល។ ក្រុមការងារ អង្គការជីវិតនៅកម្ពុជា (TLC) និងសាកលវិទ្យាល័យហុងកុង (HKU) បានជ្រើសរើសនូវសំណាកសាលារៀនលើកដំបូង ជាបន្តបន្ទាប់ដោយក្រុមការងារអង្គការជីវិតនៅកម្ពុជា (TLC) ទទួលបានការយល់ព្រមពីមន្ទីរអប់រំយុវជន និងកីឡាខេត្ត នឹងពីសាមីសាលារៀនដោយផ្ទាល់។

នៅក្នុងសំណាកសាលារៀន ការស្រាវជ្រាវបានផ្តោតទៅលើសិស្សក្នុងកម្រិតថ្នាក់ទី៩ (អនុវិទ្យាល័យទាំង៦) និងថ្នាក់ទី១២ (វិទ្យាល័យទាំង៣) មូលដ្ឋានទាំងអស់នោះ គឺជាដំណើការឆ្លងកាត់ក្នុងប្រព័ន្ធអប់រំ ដូច្នេះ គឺពិតជាមានសារៈសំខាន់ណាស់។ ថ្នាក់ទី៩ មានរៀបចំការប្រឡងថ្នាក់ជាតិដែលជាការសម្គាល់ឃើញថា ជាការបញ្ចប់ការសិក្សានៅកម្រិតអនុវិទ្យាល័យ ដែលត្រៀមបន្តទៅថ្នាក់ទី១០ ឬចាកចេញពីប្រព័ន្ធ។ ថ្នាក់ទី១២ គឺជាឆ្នាំបញ្ចប់ការសិក្សា ហើយត្រូវប្រលងថ្នាក់ជាតិជាថ្មីម្តងទៀត អាស្រ័យដោយសិស្សដែលត្រូវបន្តការសិក្សាទៅកម្រិតសាកលវិទ្យាល័យ ឬក៏សម្រេចចិត្តរកការងារធ្វើ។

សមាសភាគស្រាវជ្រាវទាំងពីរ មានបែបបរិមាណ និងគុណភាព។ ក្នុងការចុះជួបលើកដំបូងតាមសាលារៀននីមួយៗ ក្រុមការងារបានពន្យល់ទៅដល់គ្រូនិងសិស្ស ពីគោលបំណងក្នុងការជ្រើសរើសថ្នាក់រៀនសម្រាប់ការស្រាវជ្រាវ។ បន្ទាប់មក ក្រុមការងារបានសង្ខេបជូនដល់សិស្សដើម្បីឱ្យពួកគេយកព័ត៌មាននេះទៅជម្រាបជូនឪពុកម្តាយ និងទទួលបានការយល់ព្រមពីអាណាព្យាបាលរបស់ពួកគេ។ បន្ទាប់មក ក្រុមការងារបានវិលត្រលប់ទៅសាលារៀននីមួយៗ ហើយបានប្រមូលលិខិតយល់ព្រមពីសិស្ស និងគ្រូបង្រៀនក្នុងការចូលរួមការស្រាវជ្រាវនេះ។ ខណៈពេលដែលផ្តល់នូវទម្រង់សំនួរដល់សិស្ស និងគ្រូបង្រៀន មានលិខិតអញ្ជើញចូលរួមសម្ភាសន៍មួយទៀតបានចែក បន្ថែមដល់អ្នកដែលត្រូវបានជ្រើសរើស។ របាយការណ៍នេះ បានដកស្រង់ពីទម្រង់សំនួររបស់សិស្សដែលបានឆ្លើយតបមានចំនួន ១.២៧៤ នាក់ (ថ្នាក់ទី៩ មានចំនួន ៦៦២នាក់ និងថ្នាក់ទី១២ មានចំនួន ៦១២នាក់) និងមានគ្រូបង្រៀនចំនួន ៧២នាក់។ វាក៏បានដកស្រង់ចេញពីការសម្ភាសន៍សិស្សចំនួន ៨៨នាក់ និងគ្រូបង្រៀនចំនួន ២៨នាក់ផងដែរ (Bray et al ឆ្នាំ២០១៥)។

សម្រាប់ការសម្ភាសន៍សិស្ស ការសិស្សាស្រាវជ្រាវបានរៀបចំសំណាក ដែលមានតុល្យភាពតាមថ្នាក់នីមួយៗដូចការរំពឹងទុកៈ

- សិស្សប្រុសបានរៀនគួ

- សិស្សប្រុសមិនបានរៀនគូ
- សិស្សស្រីបានរៀនគូ និង
- សិស្សស្រីមិនបានរៀនគូ

ទោះជាយ៉ាងណាក៏ដោយ សិស្សមួយចំនួនដែលបានព្រមព្រៀងចូលរួមសម្ភាសន៍ ហើយបន្ទាប់មកបានសុំមិនចូលរួមវិញ គឺយើងបានជ្រើសរើសសិស្សថ្មីជំនួសវិញ។ ដូច្នេះ សាលារៀនខ្លះដែលមានការពាក់ពន្ធ័ជាមួយសិស្សមួយចំនួន គឺមិនបានទទួលការបង្រៀនគូទេ។ ហើយវាមិនងាយស្រួលដែរ ក្នុងការស្វែងរកអ្នកដែលមានឆន្ទៈក្នុងការផ្តល់បទសម្ភាសន៍ទាំងនោះ។ ទិន្នន័យចុងក្រោយ គឺជាផ្នែកមួយកំពុងឆ្លុះបញ្ចាំងពីការលើកស្ទួយសិស្សស្រីនៅក្នុងថ្នាក់រៀន មានភាពល្អប្រសើរ ហើយឆន្ទៈក្នុងការផ្តល់បទសម្ភាសន៍របស់ពួកគាត់ក៏មានភាពល្អប្រសើរដែរ។ ដោយសារពួកគាត់គឺជាសិស្សគំរូមានចំនួន ៣១នាក់ ជាសិស្សស្រី និងមានត្រឹមតែ ១៧នាក់ ជាសិស្សប្រុស។ ក្នុងនោះក៏មានសិស្សចំនួន ៣៩នាក់ កំពុងទទួលបានការបង្រៀនមេរៀនថ្នាក់គូ បើធៀបទៅនឹងចំនួន ៩នាក់ ដែលមិនបានទទួលការបង្រៀនគូ។ ទោះជាយ៉ាងណាក៏ដោយសមតុល្យទាំងនេះ បានធ្វើឡើងពីវិសាលភាពមួយចំនួន ដែលផ្ទុយផ្គងទំហំនៃតារាងបង្ហាញលើទិន្នន័យបែបបរិមាណ។

ផ្ទុយយពីខាងលើ ការសម្ភាសន៍គ្រូបង្រៀនបានរក្សាសមភាពយេនឌ័រក្នុងចំណោមអ្នកផ្តល់បទសម្ភាស៍ចំនួន ២៤នាក់ ដែលមាន១២នាក់ (៥០.0%) ជាស្ត្រី និង ១២នាក់ (៥០.0%) ជាបុរស។ ការប្រៀបធៀបនេះ គឺជាមធ្យមភាគនៃចំនួន៤៦.៦% គឺជាស្ត្រីក្នុងចំណោមគ្រូបង្រៀននៅអនុវិទ្យាល័យក្នុងខេត្ត ក៏ដូចជាទូទាំងខេត្តទាំងមូល។ ក្នុងចំណោមគ្រូបង្រៀនដែលបានសម្ភាសន៍មានចំនួន១១នាក់ (៥៥.០%) បានផ្តល់ ការបង្រៀនគូរ។ ហើយចំនួនប្រាំបួននាក់(៤៥.០%) គឺ មិនបានបង្រៀនគូទេ។

## ៣. ទំហំ និងហេតុផលសម្រាប់ការស្វែងរកការផ្តល់មេរៀនបន្ថែម

ក្នុងចំណោមការឆ្លើយតបរបស់សិស្សលើកម្រងសំនួរ មានចំនួន៨១.៩% បានប្រាប់ថាពួកគេទទួលបានការបង្រៀនគួ គឺថ្នាក់ទី១២មានចំនួនខ្ពស់ជាង ថ្នាក់ទី៩(តារាងទី១)។ ការខុសប្លែកគ្នារវាងយេនឌ័រ គឺមានកម្រិតទាបទោះបី ជាមានតួរលេខខ្ពស់បន្តិចបន្តួច ក្នុងចំណោមសិស្សស្រីក៏ដោយ។

***តារាងទី១៖*** *ទំហំនៃការរៀនមេរៀនថ្នាក់គួ*

| | | សមាមាត្រនៃការទទួលបានការបង្រៀនគួ (ភាគរយ) |
|---|---|---|
| **សិស្សទាំងអស់** | | **៨១.៩** |
| ថ្នាក់ | ថ្នាក់ទី៩ | ៧៤.៧ |
| | ថ្នាក់ទី៩ | ៨៩.៨ |
| យេនឌ័រ | ប្រុស | ៨០.៩ |
| | ស្រី | ៨២.៨ |
| ទីតាំង | ទីក្រុង ទីប្រជុំជនជនបទ | ៨៣.៥ |
| | ទីដាច់ស្រយាល | ៨០.៩ |

*តារាងទី១* ក៏បានបង្ហាញថា សមាមាត្រសិស្សស្រីនៅក្នុងទីក្រុងដែលបានទទួលការបង្រៀនគួមានភាពល្អប្រសើរជាង បើធៀបជាមួយនឹងតំបន់ផ្សេងទៀតដែលមានភាពប្រហាក់ប្រហែលគ្នា។ នេះគឺស្របគ្នាជាមួយនឹងបរិបទនៅប្រទេសដទៃផ្សេងទៀត (ឧទាហរណ៍ Bray និង Lykins ឆ្នាំ២០១២, p.១២) ប៉ុន្តែគម្លាតនេះ គឺមានតិចតួច។ ហេតុផលសមរម្យមួយនៃគម្លាតនេះ គឺការបង្រៀនភាគច្រើនត្រូវបានផ្តល់ដោយគ្រូបង្រៀន ជាជាងក្រុមហ៊ុនដែលមានទំនោរនៅក្នុងទីក្រុងដោយសារមានចំនួនប្រជាជនច្រើន។ ការកំណត់សំនួរពីការបង្រៀន គឺយោងតាមការកែសម្រួលទម្រង់សំនួរឱ្យបានត្រឹមត្រូវ ហើយបានសួរតែសាលារៀនចំនួន ៣ នៃសាលារៀនចំនួនប្រាំមួយ (ទីប្រជុំជនមួយ ជនបទមួយ និងទីដាច់ស្រយាល់មួយ) ប៉ុន្តែក្នុងចំណោមការឆ្លើយតបរបស់សិស្សនៅតាមសាលារៀនទាំងអស់នោះក្នុងការទទួលរបង្រៀនគួ គឺមានចំនួន ៥៧.៧% បានបង្ហាញថាពួកគេបានរៀនគួ ជាមួយនឹងគ្រូបង្រៀនរបស់ពួកគេផ្ទាល់។ ហើយ៤០.៩% គឺបានរៀនជាមួយគ្រូដទៃទៀត មកពីសាលាជាមួយគ្នា។ មានតែ១.២%ប៉ុណ្ណោះ បានបង្ហាញថាពួកគេបានទទួលការបង្រៀនពីគ្រូបង្រៀនមកពីសាលាផ្សេង និងមាន០.៦% ជានិស្សិតសាកលវិទ្យាល័យ ឬបុគ្គលធ្វើការងារដោយខ្លួនឯង និងមិនមានមកពីក្រុមហ៊ុនទេ។

ការសម្ភាសសិស្សនិងគ្រូបង្រៀនបានបង្ហាញថា ការបង្រៀនគួភាគច្រើនគឺបានបង្រៀន នៅក្នុងសាលាកន្លងមក ដោយសិស្សនិងគ្រូទាំងអស់នោះ។ ជួនកាលត្រូវបានបង្រៀននៅផ្ទះរបស់គ្រូបង្រៀនតែម្តង ឬក៏ទីតាំងផ្សេងទៀត ដូចជានៅក្នុងការិយាល័យអង្គការមិនមែនរដ្ឋាភិបាល។ នៅក្នុង

ផ្នែកមួយនៃប្រទេសកម្ពុជា កន្លែងដែលផ្តល់ការបង្រៀនជាច្រើន គឺត្រូវបានផ្តល់ដោយក្រុមហ៊ុន (ជាពិសេសរាជធានីភ្នំពេញ) ដែលការបង្រៀននេះ ជាទូទៅកើតឡើងតាមការចាត់ចែងដោយក្រុមហ៊ុនទាំងនោះ។ ទោះជាយ៉ាងណាក៏ដោយ ភាពពិតដែលថាការបង្រៀនភាគច្រើននៅក្នុងសាលារៀនចំនួនប្រាំមួយដែលបានស្ទង់មតិខាងលើនេះ បានធ្វើឡើងនៅតាមសាលារៀនរបស់ពួកគេផ្ទាល់មានន័យថាថ្នាក់រៀនគួរអាចត្រូវបានមើលឃើញយ៉ាងជាក់ច្បាស់ថាមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងសាលារដ្ឋ។ សិស្សភាគច្រើនដែលទទួលបានការបង្រៀនគួជាទូទៅ មានមុខវិជ្ជាជាច្រើន (តារាងទី២)។ ជិតពាក់កណ្តាលនៃអ្នកបានទទួលការបង្រៀនមេរៀនថ្នាក់គួ ចាប់ពីពីរ បីទៅប្រាំមុខវិជ្ជា ហើយមានចំនួន ១.៧% នៃសិស្សទាំងនោះ គឺបានរៀនលើសពីប្រាំមួយមុខវិជ្ជា។ មិនមែនត្រឹមតែសិស្សថ្នាក់ទី១២នោះទេ ដែលទទួលបានការបង្រៀនគួច្រើនមុខវិជ្ជា។ ពួកគាត់ក៏បានទទួលការបង្រៀនលើមុខវិជ្ជាច្រើនផងដែរ។ មានចំនួន៥៥.៣% នៃពួកគេបានរៀបរាប់ថា ពួកគាត់បានទទួលការបង្រៀនមុខវិជ្ជាលើសពីប្រាំមួយមុខវិជ្ជា ខណៈពេលដែលសិស្សឡើងថ្នាក់ទី៩ មានចំនួនត្រឹមតែ ៨.១% ប៉ុណ្ណោះ។ មានមុខវិជ្ជាគណិតវិទ្យា គីមីវិទ្យា ភាសាខ្មែរ (ភាសា និងអក្សរសាស្ត្រ) រូបវិទ្យា ជីវវិទ្យា និងភាសាអង់គ្លេស គឺជាមុខវិជ្ជាពេញនិយមបំផុតសម្រាប់ការបង្រៀនគួ។

***តារាងទី២*** *មុខវិជ្ជាបង្រៀនគួ*

| ចំនួននៃមុខវិជ្ជា | លេខ | ភាគរយ | មុខវិជ្ជា | ចំនួន | ភាគរយ* |
|---|---|---|---|---|---|
| សូន្យ (គ្មានបង្រៀនគួ) | ២៣០ | ១៨.១ | គណិតវិទ្យា | ៨២៥ | ៧៩.០ |
| មួយ | ១៧១ | ១៣.៤ | គីមីវិទ្យា | ៧១៨ | ៦៨.៨ |
| ពីរ | ១២៩ | ១០.១ | ខ្មែរ | ៦២៧ | ៦០.១ |
| បី | ២១៥ | ១៦.៩ | រូបវិទ្យា | ៦២៣ | ៥៩.៧ |
| បួន | ១៩៧ | ១៥.៥ | ជីវៈវិទ្យា | ៤៦១ | ៤៤.២ |
| ប្រាំ | ២១៨ | ១៧.១ | ភាសាអង់គ្លេស | ២៩៦ | ២៨.៤ |
| ប្រាំមួយ | ៩១ | ៧.១ | ផែនដីវិទ្យា នឹងការសិក្សាបរិស្ថាន | ៤៧ | ៤.៥ |
| ច្រើនជាងប្រាំមួយ | ២២ | ១.៧ | ភូមិវិទ្យា | ៣៥ | ៣.៤ |
| បាត់បង់ | ១ | ០.១ | ប្រវត្តិវិទ្យា | ២៨ | ២.៧ |
| សំណាកសិស្ស | ១,២៧៤ | ១០០.០ | សីលធម៌/ទស្សនៈវិទ្យា | ១៥ | ១.៤ |
| | | | ផ្សេងៗ | ២ | ០.២ |

*ការបង្ហាញជាភាគរយរបស់សិស្សដែលទទួលបានការបង្រៀនគួ ឧទាហរណ៍ មិនរាប់បញ្ចូលអ្នកដែលមិនបានទទួលការបង្រៀនគួ។

***តារាងទី៣*** *ហេតុផលរបស់សិស្សក្នុងការទទួលបានការបង្រៀនគួ*

| ហេតុលផល | ថ្នាក់ទី៩ | | ថ្នាក់ទី១២ | |
|---|---|---|---|---|
| | ចំនួនភាគរយ* | សំខាន់* | ចំនួនភាគរយ* | សំខាន់* |
| ត្រៀមសម្រាប់ការប្រលងថ្នាក់ជាតិ | ៨៩.៥ | ១ | ៩៧.៣ | ១ |
| ទទួលបានវិធីសាស្ត្រគរុកោសល្យផ្សេងគ្នា | ៨៧.៦ | ២ | ៩២.០ | ២ |
| បង្កើនចំនួនម៉ោងសិក្សាបន្ថែមដែលខ្ញុំបានទទួល | ៨២.៩ | ៣ | ៨៧.១ | ៤ |
| ដើម្បីត្រៀមសម្រាប់ចូលរៀននៅសាកលវិទ្យាល័យ | ៧៧.៩ | ៤ | ៧៨.៤ | ៣ |
| បទពិសោធន៍គឺថ្នាក់រៀនតូចជាងថ្នាក់សាលារៀនរដ្ឋ | ៦៨.៦ | ៦ | ៧៥.៩ | ៥ |
| បំពេញតម្រូវការឪពុកម្ដាយរបស់ខ្ញុំ | ៧២.៧ | ៥ | ៦៣.៥ | ៦ |
| បំពេញតម្រូវការពីគ្រូបង្រៀនរបស់ខ្ញុំ | ៣១.៨ | ៧ | ២៤.៥ | ៨ |
| បង្កើនចំណូលគ្រូបង្រៀនរបស់ខ្ញុំ | ២៩.៨ | ៨ | ២៤.៩ | ៧ |

*ចំនួនភាគរយ នៃសិស្សដែលបានយល់ព្រម ឬមានការយល់ព្រមយ៉ាងមុតមាំជាមួយនឹងហេតុផលនេះ ក្នុងចំណោមអ្នកដែលបានឆ្លើយតបទៅនឹងសំនួរនេះ។
*ចំណាត់ថ្នាក់ នៃភាពសំខាន់៖ មានសារៈសំខាន់បំផុតមានចំនួន១ និងមានសារៈសំខាន់តិចតួចមានចំនួន៨។

ការទាក់ទងនឹងហេតុផលរបស់សិស្សដែលស្វែងរកការបង្រៀនគួតារាងទី៣ បានបង្ហាញពីសារៈសំខាន់នៃការប្រឡងថ្នាក់ជាតិ ជាពិសេសសម្រាប់សិស្សថ្នាក់ទី១២។ ហេតុផលទីពីរ គឺដើម្បីទទួលបាននូវការបង្រៀនដែលប្រើវិធីសាស្ត្រគរុកោសល្យផ្សេងគ្នា មានន័យថាគ្រូបង្រៀនបានបង្រៀនខុសគ្នានៅក្នុងថ្នាក់គួ។ មូលហេតុចំបងបំផុតគឺ ដើម្បីបង្កើនចំនួនពេលវេលាបន្ថែមសម្រាប់សិក្សា។

## ៤. តើអ្វីខ្លះដែលសិស្សទទួលបានពីថ្នាក់រៀនគួ

កម្មវិធីសិក្សានៅសាលារដ្ឋ គឺបានទទួលស្គាល់យ៉ាងទូលំទូលាយដើម្បីឱ្យមានពេលវេលាពេញលេញដែលអាចប្រើប្រាស់បាន។ ចំនួនថ្ងៃរៀននៅសាលា មានរយៈពេលខ្លីបើប្រៀបធៀបជាមួយប្រទេសដទៃទៀត។ ប្រព័ន្ធសាធារណៈ និងថ្ងៃឈប់សម្រាកមានច្រើន ហើយជាទូទៅចំនួនថ្ងៃគឺត្រូវបានបាត់បង់ដោយសារអវត្តមានរបស់គ្រូបង្រៀន និងកត្តាផ្សេងៗទៀត។ គ្រូបង្រៀនត្រូវបានគេរំពឹងថា នឹងបញ្ចប់កម្មវិធីសិក្សាក្នុងរយៈពេលនៃឆ្នាំសិក្សារបស់ខ្លួន។ ប៉ុន្តែតម្រូវការនេះនាំឱ្យពួកគាត់ប្រញាប់ប្រញាល់ ដើម្បីបញ្ចប់កម្មវិធីសិក្សាឱ្យទាន់ពេលវេលា។ ថ្នាក់គួបានផ្តល់នូវពេលវេលាបន្ថែមសម្រាប់សិស្ស និងអនុញ្ញាតឱ្យពួកគេរំលឹកមេរៀនឡើងវិញ នូវអ្វីដែលពួកគេបានរៀន និងជាពិសេសបានផ្តល់នូវលំហាត់ជាច្រើនសម្រាប់ពង្រឹងសម្ថភាព ដែលនេះគឺជាការទទួលបានការពន្យល់ពីសិស្សម្នាក់ដូចខាងក្រោមៈ

*«ខ្ញុំមានអារម្មណ៍ថាសម្រាប់មុខវិជ្ជាជីវៈវិទ្យា យើងមិនបានសិក្សាលំហាត់ក្នុងសាលារដ្ឋ [ទៀងទាត់]ទេ។ យើងមានលំហាត់តិចតួចប៉ុណ្ណោះ ដូច្នេះប្រសិនបើយើងមិនទៅរៀនគួទេ យើងនឹងមិនយល់អ្វីទាំងអស់។ ខ្ញុំមិនដឹងពីរបៀបដោះស្រាយលំហាត់នៅពេលដែលខ្ញុំប្រឡង។»*

មានសិស្សដទៃទៀតបានបង្ហាញថា «នៅក្នុងថ្នាក់រៀនគួ[គ្រូបង្រៀន] បានពន្យល់នូវចំណុចនីមួយៗយ៉ាងច្បាស់ ហើយយើងអាចសួរពួកគាត់បាន បើយើងមិនច្បាស់ត្រង់ណា ។» ភាពផ្ទុយគ្នានេះ គឺជារូបភាពកើតមាននៅក្នុងថ្នាក់របស់រដ្ឋដែលពេលវេលារឹតបន្តឹង ហើយមានការលាក់បាំងកម្មវិធីសិក្សា ដោយមិនលើកទឹកចិត្តឱ្យសិស្សសួរសំណួរច្រើន។

ខណៈពេលដែលគ្រូបង្រៀនភាគច្រើនឆ្លើយតបនឹងកម្រងសំណួរ និងនៅក្នុងការសម្ភាសន៍បានបង្ហាញថា ពួកគេអាចធ្វើបានហើយបានបញ្ចប់កម្មវិធីសិក្សានៅក្នុងថ្នាក់រៀនរបស់រដ្ឋ បើទោះបីជាលឿនទាន់ពេលវេលាកំណត់ក៏ដោយ ក្រុមអ្នកស្រាវជ្រាវបានឮពីសិស្ស ក៏ដូចជាគ្រូបង្រៀនមួយចំនួន អំពីករណីដែលគ្រូបង្រៀនមួយចំនួនមានចេតនា "រក្សាទុក" មេរៀនពីសាលារដ្ឋ និងបានយកទៅប្រើប្រាស់នៅក្នុងថ្នាក់រៀនគួ។ សិស្សម្នាក់បានបញ្ជាក់ថាៈ « គ្រូបាននិយាយថាប្រសិនបើអ្នកចង់ចេះច្បាស់ អ្នកអាចទៅរៀនគួជាមួយថ្នាក់របស់ខ្ញុំ »។ សិស្សម្នាក់ទៀតបានបង្ហាញថា គ្រូបង្រៀន "មិនអនុញ្ញាតឱ្យ" សិស្សធ្វើលំហាត់នៅក្នុងថ្នាក់រដ្ឋទេ ទោះបីជាមានពេលក៏ដោយ។ ផ្ទុយទៅវិញ នៅពេលដែលគ្រូបង្រៀនបានបញ្ចប់មាតិកាដែលពួកគាត់ត្រូវបញ្ចប់ ពួកគាត់ក៏ធ្វើដូចបានបិទមេរៀននេះដែរៈ

*គ្រូបង្រៀនមួយចំនួន មិនផ្តល់លំហាត់ដល់យើងទេ ទោះបីជាពួកគេបានបញ្ចប់ [ថ្នាក់រដ្ឋ] មេរៀនរួចហើយក៏ដោយ ...។ ពួកគាត់អនុញ្ញាតឱ្យសិស្សសម្រាកជំនួសវិញ។ ខ្ញុំគិតថាពួកគាត់គួរតែផ្តល់លំហាត់តូចឱ្យសិស្សឱ្យបានសមរម្យ។*

ធាតុផ្សំបន្ថែមលើការព្រួយបារម្ភណ៍នេះ គឺបានគ្របដណ្តប់ដោយគម្រោងនៅក្នុងមេរៀនថ្នាក់រៀនគួ ដែលវាលើសលុបលើថ្នាក់រដ្ឋ។ សិស្សម្នាក់បានពន្យល់ថាៈ

*ជាធម្មតាគ្រូបានបង្រៀនមេរៀននៅក្នុងថ្នាក់គួ មុនពេលយកមកបង្រៀននៅក្នុងថ្នាក់រដ្ឋ។ បន្ទាប់មក គ្រូបង្រៀនយកមេរៀនទៅបង្រៀនក្នុងថ្នាក់រដ្ឋ ហើយគ្រូបានហៅសិស្សដែលបានរៀនគួ ដើម្បីឡើងដោះស្រាយលំហាត់ ពីព្រោះដោយសារតែសិស្ស ដែលមិនរៀនគួគឺ មិនបានដឹងពីរបៀបក្នុងការដោះស្រាយលំហាត់នោះទេ។ ជាលទ្ធផល គឺយើងមិនអាចយល់ ហើយគ្រូបង្រៀនក៏មិនបានពន្យល់ឱ្យបានក្បោះក្បាយនោះដែរ...។ [ជាប់ទាក់ទងគ្រូ] ទង្វើប្រភេទនេះ គឺមានគោលបំណងដើម្បីជំរុញឱ្យសិស្សទៅរៀនគួជាមួយពួកគាត់។*

ការបង្ហាញកម្រិតខ្ពស់ ដែលផ្តល់ឱ្យការបង្រៀនសិស្សត្រូវបានគេឱ្យនិយមន័យថាជាល្បិចទីផ្សារដទៃទៀត។ មានសិស្សម្នាក់ទៀត បានពន្យល់ថា៖

*សិស្សដែលបានបំពេញមុខវិជ្ជាគួ គឺទទួលបានពិន្ទុខ្ពស់ជាងសិស្សដែលមិនបានរៀនគួរ។ គ្រូបង្រៀន នឹងដាក់ពិន្ទុបន្ថែមទៅដល់សិស្សណាដែលបានរៀនគួ។*

គ្រូបង្រៀនក៏ទទួលស្គាល់ផងដែរនូវការអនុវត្តនេះ។ ដូចបានរៀបរាប់ដោយគ្រូម្នាក់ថា៖

*ជាធម្មតាសិស្ស ដែលបានរៀននៅថ្នាក់គួ គឺត្រូវបានផ្តល់ពិន្ទុខ្ពស់ បើទោះជាពិន្ទុ [ពិតប្រាកដ] របស់ពួកគេមិនបានល្អក៏ដោយ។ ប៉ុន្តែសិស្សដែលមិនបានសិក្សានៅថ្នាក់គួ គឺមិនបានទទួលពិន្ទុនោះទេ។*

ក្នុងករណីទាំងនេះ គ្រូបានប្រើប្រាស់អំណាចរបស់ពួកគាត់ដើម្បីកំណត់ និងការធ្វើការប្រលងផ្ទៃក្នុង ទោះបីជាពិន្ទុដែលបានបញ្ចូនទាំងអស់នោះ មិនយកបូកជាមួយនឹងពិន្ទុដែលបានទទួលដោយសិស្សក្នុងការប្រលងថ្នាក់ជាតិក៏ដោយ។ តាមរយៈពិន្ទុបន្ថែម គឺសំដៅទៅលើសិស្សដែលបានទទួលមេរៀនពីគ្រូរបស់ពួកគាត់ផ្ទាល់។ សក្តានុពលនៅក្នុងករណី នៃការសិក្សាពីគ្រូផ្សេងទៀតអាចនឹងមានភាពខុសគ្នា ប៉ុន្តែភាពស្របនៃការសិក្សា គឺនៅតែជៀសមិនរួចពីផលអាក្រក់មកលើសាលារដ្ឋ។

សមាសភាគបន្ថែមទៀតនូវអ្វីដែលសិស្សទទួលបាននៅក្នុងការរៀនគួ គឺជាវិធីសាស្រ្តតម្រង់ទិសសិស្សឱ្យចូលរៀនកាន់តែច្រើន។ ក្នុងអំឡុងពេលរៀនគួ គ្រូបង្រៀនហាក់បីដូចជាមានភាពសាមញ្ញ និងមានភាពរហ័សរហួន ហើយមានឆន្ទៈក្នុងការជួយជាលក្ខណៈបុគ្គលច្រើនជាង។ ពួកគាត់បានទទួលស្គាល់ថា ពួកគាត់នៅលើទីផ្សារតែមួយហើយសិស្សទាំងអស់នោះមានជម្រើសសម្រាប់ការមិនរៀនគួ ឬអាចរៀនគួដែរតែរៀនជាមួយនឹងគ្រូផ្សេងទៀត។

## ៥. ការជាប់ទាក់ទងគ្នាសម្រាប់អ្នកធ្វើគោលនយោបាយ

អាទិភាពនៃភាពស្របគ្នានៃមេរៀនថ្នាក់រៀនគួ គឺជាបញ្ហាយ៉ាងសំខាន់។ កម្ពុជាគួរកំណត់គោលដៅសម្រាប់គ្រប់គ្រងប្រព័ន្ធសាលារដ្ឋឱ្យលក្ខណៈគ្រប់គ្រាន់ ដែលសិស្សមិនមានអារម្មណ៍ថាពួកគាត់ គឺមិនត្រូវការថ្នាក់បន្ថែមម៉ោង។

ដើម្បីសម្រេចគោលដៅនេះបាន អ្នកបង្កើតគោលនយោបាយត្រូវពិចារណាចំណុចដូចខាងក្រោម៖

*ចំនួនម៉ោងក្នុងថ្ងៃសិក្សានៅសាលារៀន និងចំនួនថ្ងៃក្នុងឆ្នាំសិក្សា៖* សាលារៀន និងគ្រូបង្រៀនត្រូវការពេលវេលាគ្រប់គ្រាន់ ដើម្បីបញ្ចប់កម្មវិធីសិក្សាជាមួយនឹងលំហាត់ដែលចាំបាច់។ គណៈគ្រប់គ្រងសាលា គួរតែពង្រីកទាំងថ្ងៃរៀននៅក្នុងសាលា និងចំនួនថ្ងៃសិក្សាពេញមួយឆ្នាំ។

*ប្រាក់ខែគ្រូបង្រៀន៖* ជាទូទៅ គ្រូបង្រៀនជំរុញឱ្យសិស្សរបស់ពួកគាត់រៀនគួក្នុងគោលបំណងដើម្បីរកប្រាក់ចំណូលបន្ថែម។ ពួកគាត់បានធ្វើរបៀបនេះរួចហើយកន្លងមក ជាមួយនឹងអំពើទុច្ចរិតមួយចំនួន ដោយសារប្រាក់ខែរបស់ពួកគាត់មានកម្រិតទាប ហើយការដំឡើងប្រាក់បៀវត្សមិនគ្រប់គ្រាន់តាមកាលកំណត់ និងការកាត់ជាអតិផរណា។ កាលពីខែមេសាឆ្នាំ ២០១៦ រដ្ឋាភិបាលបានដំឡើងបៀវត្សថ្មីមួយទៀតគួរអោយកត់សម្គាល់។ នេះអាចប្រហែលជាទម្រង់កិច្ចសន្យាសង្គមគឺនឹងត្រូវបានប្រើដើម្បីបញ្ចុះបញ្ចូលគ្រូបង្រៀនឱ្យបំពេញភារៈកិច្ចរបស់ខ្លួនបានទៀងទាត់ និងកាន់តែយកចិត្តទុកដាក់យ៉ាងមុតមាំ។ ជាការពិតណាស់ ថវិការបស់រដ្ឋាភិបាល មានការបង្គាប់បញ្ជា និង វាមិនងាយស្រួលក្នុងការស្មើឡើងទេ។ ទៅកាន់កម្រិតណាមួយដែលគ្រូបង្រៀនមានអារម្មណ៍ថា ពេញចិត្តដោយគ្មានការផ្តល់នូវប្រាក់ចំណូលណាមួយនោះ។ ទោះជាយ៉ាងណាក៏ដោយ ជាករណីកំពុងជួបប្រទះដ៏ធំដែលនៅសែសសល់មួយ គឺការលើកឡើងលើប្រាក់ខែរបស់គ្រូបង្រៀន (នៅក្នុងលក្ខខ័ណ្ឌពិតប្រាកដ ឧទាហរណ៍ មិនមែនគ្រាន់តែតាមរយៈការបំប៉ោងទេ) ដូច្នេះគ្រូបង្រៀនគ្មានជម្រើស និងដំណោះស្រាយក្រៅពីការជំរុញឱ្យសិស្សទៅរៀនគួនោះទេ។

*គ្រូបង្រៀនគួដល់សិស្សផ្ទាល់ខ្លួន៖* ការអនុវត្តរបស់គ្រូបង្រៀន ដែលបង្រៀនមេរៀនបន្ថែមដល់សិស្សរបស់ខ្លួននេះ គឺជាបញ្ហាចំបង។ វាធ្វើឱ្យមានទំនាក់ទំនងយ៉ាងជិតស្និតរវាងសាលារដ្ឋ និងថ្នាក់រៀនគួ ហើយវាបានចូលរួមចំណែកដល់អំពើពុករលួយ ដែលក្នុងនោះគ្រូបង្រៀនមានចេតនាបដិសេធមាតិកាបង្រៀនពីថ្នាក់រដ្ឋ និងមានចេតនាបំផុសបំផុលសិស្សឱ្យទៅរៀនគួរ។ វាគឺពិតជាមិនអាចធ្វើទៅបានទេក្នុងពេលបច្ចុប្បន្ននេះ ដើម្បីហាមឃាត់គ្រូរដ្ឋមិនឱ្យមានការបង្រៀនគួនោះ។ ប៉ុន្តែយ៉ាងហោចណាស់ អាចហាមឃាត់បានពីការបង្រៀនសិស្សរបស់ពួកគាត់ផ្ទាល់។

## ៦. ផលប៉ះពាល់សម្រាប់អ្នកគ្រប់គ្រងសាលា

គោលនយោបាយនៅថ្នាក់ខេត្ត និងថ្នាក់ជាតិ គឺមានតួនាទីសំខាន់ណាស់ ប៉ុន្តែអ្វីដែលសំខាន់ជាងនេះទៅទៀតគឺ ជាគោលនយោបាយនិងការអនុវត្តនៃការគ្រប់គ្រងសាលារៀន។ ការស្រាវជ្រាវនេះ បានសួរសិស្សនិងគ្រូបង្រៀននូវអ្វីដែលគោលការណ៍សាលារបស់ពួកគាត់ និងអ្នកគ្រប់គ្រងផ្សេងទៀតអំពីការរៀនគួ។ ការឆ្លើយតបភាគច្រើនបាន ង្ហាញថា អ្នកគ្រប់គ្រងសាលាមានការយោគយល់ច្រើន ពោះការប្រព្រឹត្តនេះ ហើយសកម្មភាពមួយចំនួនបានលើកទឹកចិត្តដោយសារតែ (ក) វាបានលើកកម្ពស់ការសិក្សាដល់សិស្ស (មួយចំនួន) និង (ខ) ផ្តល់ប្រាក់ចំណូលបន្ថែមសម្រាប់គ្រូបង្រៀន ដែលជាទូទៅត្រូវបានគេចាត់ទុកថា មានប្រាក់ឈ្នួលមិនគ្រាប់គ្រាន់ពីសាលារដ្ឋ។

ទោះជាយ៉ាងណាក៏ដោយ អ្នកគ្រប់គ្រងសាលាគួរពិចារណានូវចំណុចអវិជ្ជមានលើភាពស្របគ្នាក្នុងការបង្រៀនគួ និងមានផលប៉ះពាល់ទៅលើសិស្ស ដែលមិនអាចមានលទ្ធភាពបង់ថ្លៃរៀនគួ នៅក្នុងវិសមភាពផ្ទៃក្នុង នៅពេលដែលគ្រូបង្រៀនមួយចំនួនតម្រូវឱ្យបើកថ្នាក់គួ ដោយមិនមានការយកចិត្តទុកដាក់ពីអ្នកដទៃនោះ និងគ្មានប្រសិទ្ធភាពក្នុងការប្រើប្រាស់ពេលវេលាសម្រាប់សិស្ស និងគ្រូបង្រៀន។ ជាមួយនឹងកង្វល់នេះ អ្នកគ្រប់គ្រងសាលារៀនគួតែពិចារណាចំណុចដូចខាងក្រោម៖

- *ការហាមឃាត់ចំពោះការផ្តល់នូវមេរៀនបន្ថែមដល់សិស្សផ្ទាល់ខ្លួន:* បើទោះបីជាថ្នាក់ខេត្ត ឬ ថ្នាក់ជាតិមិនទាន់បានបង្កើតគោលនយោបាយមួយនេះ (នៅឡើយ) សាលាអាចមាននូវគោលនយោបាយនេះដោយផ្ទាល់ខ្លួនឯង ជាការពិតណាស់ នេះគឺជារឿងធម្មតានៅក្នុងបណ្តាប្រទេសផ្សេងទៀត។ សកម្មភាពដំបូងបានយកមកពីកម្រិតសាលា ដើម្បីជៀសវាងការជះឥទ្ធិពលលើការប្រព្រឹត្តអំពើពុករលួយ សម្រាប់ការទទួលបានប្រាក់ចំណូលរបស់គ្រូ ពីការបង្រៀនសិស្សផ្ទាល់ខ្លួនរបស់ពួកគាត់។
- *លើកទឹកចិត្តគ្រូបង្រៀនឱ្យមានចិត្តអាណិតអាសូរដល់សិស្សដែលមានប្រាក់ចំណូលទាប:* ក្នុងការឆ្លើយតបសំនួរពីលោកគ្រូលើសពាក់កណ្តាល (៥៦.១%) បានបង្ហាញថាពួកគេបានអនុញ្ញាតឱ្យកុមារមកពីគ្រួសារដែលមានប្រាក់ចំណូលទាប ដើម្បីទទួលបានការរៀនគួដោយបញ្ចុះតម្លៃ ឬដោយឥតគិតថ្លៃតែម្តង។ ការអនុវត្តនេះ វាហាក់បីដូចជាបង្ហាញពីភាពប្រែប្រួលគួរឱ្យកត់សំគាល់ថា មានវិសមភាពសង្គម។
- *ការគ្រប់គ្រងគុណភាពនៃការបង្រៀនគួរបស់គ្រូបង្រៀន:* ប្រសិនបើទីផ្សារការបង្រៀនគួមិនមានការទប់ស្កាត់ គ្រូបង្រៀនអាចឈានទៅកម្រិតថ្នាក់ដែលក្នុងគោលបំណង ដើម្បីបង្កើនការផ្តល់ថ្នាក់រៀនគួដល់សិស្ស ដើម្បីទទួលបានការបង្រៀនគួ និងតម្រូវការមុខវិជ្ជាអាចនឹងមានតម្លៃទាបជាង។ អ្នកគ្រប់គ្រងសាលារៀន គួរតែត្រួតពិនិត្យរឿងនេះនិងធានាសមគុណសមរម្យមួយ។
- *ការផ្តល់ប្រឹក្សានិងស្តាប់ឪពុកម្តាយ:* ក្រុមគ្រួសាររបស់សិស្ស គឺជាភាគីពាក់ព័ន្ធសំខាន់ណាស់ និងតែងតែធ្វើការសម្រេចចិត្តមិនបានល្អ។ ឧទាហរណ៍ ឪពុកម្តាយព្យាយាមទៅ

រកគ្រូដែលកំពុងបង្រៀនកូនរបស់ពួកគាត់ស្រេចហើយនោះ និងសុំឱ្យគ្រូជួយបង្រៀនផ្តល់នូវមេរៀនថ្នាក់រៀនគួ បន្ថែមទៀត។ នេះគឺជាការបង្កើតឱ្យមានទំនាស់ផលប្រយោជន៍ និងគ្មានវិសមភាពនៅក្នុងប្រព័ន្ធអប់រំ។ អ្នកគ្រប់គ្រងសាលា អាចសង្ខេបជូនឪពុកម្តាយលើបញ្ហានេះ ហើយស្តាប់ពីការយល់ឃើញ និង យោបលអំពីមធ្យោបាយបន្តទៀត។

- *ការចែករំលែកការយល់ដឹងជាមួយសាលាផ្សេងទៀត:* បញ្ហាគឺស្មុគស្មាញ និងត្រូវបានពិភាក្សាដោយបើកចំហរជាជាងការលាក់បាំង។ អ្នកគ្រប់គ្រងសាលា អាចទទួលបានការចែករំលែកច្រើនជាមួយដៃគូរ។ ទោះបីជាសាលារៀននីមួយៗមានវិសាលភាពផ្សេងគ្នាក៏ដោយ ក៏សាលាទាំងនោះមានលក្ខណៈរួមដូចគ្នា និងដែលអាចធ្វើទៅបាន។

## ៧. ការសន្និដ្ឋាន

របាយការណ៍នេះ បានបង្ហាញត្រឹមតែសេចក្តីសង្ខេបនៃសំណុំទិន្នន័យខ្ពស់មួយ ដែលបានរៀបចំឡើងនូវការណែនាំដំបូងខ្លះៗអំពីការជាប់ទាក់ទងគ្នា។ ការស្រាវជ្រាវនេះ បានបញ្ជាក់ពីការខុសប្លែកគ្នាលើភាពស្របគ្នានៃមេរៀនថ្នាក់គួ ដែលមានតម្រូវយកចិត្តទុកដាក់ឱ្យបានច្រើនទាំងនៅកម្រិតសាលា និងនៅកម្រិតខ្ពស់ជាងនេះ។

# ឯកសារយោង


Bray, Mark & Bunly, Seng (2005): *Balancing the Books: Household Financing of Basic Education in Cambodia*. Hong Kong: Comparative Education Research Centre, សាកលវិទ្យាល័យហុងកុង and Washington DC: The World Bank. [Also available in Khmer]

Bray, Mark; Kobakhidze, Nutsa; Liu Junyan & Zhang Wei (2016): 'The Internal Dynamics of Privatised Public Education: Fee-charging Supplementary Tutoring Provided by Teachers in Cambodia'. *International Journal of Educational Development*, Vol.49 in press.

Bray, Mark & Lykins, Chad (2012): *Shadow Education: Private Supplementary Tutoring and its Implications for Policy Makers in Asia*. Mandaluyong City: Asian Development Bank and Hong Kong: Comparative Education Research Centre, សាកលវិទ្យាល័យហុងកុង.

Bray, Mark; Zhang, Wei; Kobakhidze, Magda Nutsa & Liu, Junyan (2015): 'Researching Private Supplementary Tutoring in Cambodia: Contexts, Instruments and Approaches', in Bray, Mark; Kwo, Ora & Jokić, Boris (eds.), *Researching Private Supplementary Tutoring: Methodological Lessons from Diverse Cultures*. Hong Kong: Comparative Education Research Centre, សាកលវិទ្យាល័យហុងកុង, and Dordrecht: Springer, pp.219-244.

Brehm, William C.; Silova, Iveta & Tuot, Mono (2012): *The Public-Private Education System in Cambodia: The Impact and Implications of Complementary Tutoring*. Budapest: Education Support Program, Open Society Foundations.

Dawson, Walter (2009): 'The Tricks of the Teacher: Shadow Education and Corruption in Cambodia', in Heyneman, Stephen P. (ed.), *Buying Your Way into Heaven: Education and Corruption in International Perspective*. Rotterdam: Sense, pp.51-74.

Jokić, Boris (ed.) (2013): *Emerging from the Shadow: A Comparative Qualitative Exploration of Private Tutoring in Eurasia*. Zagreb: Network of Education Policy Centers.

NGO Education Partnership (2007): *The Impact of Informal School Fees on Family Expenditure*. Phnom Penh: NGO Education Partnership.

UNDP (2014): *Curbing Private Tutoring and Informal Fees in Cambodia's Basic Education*. Phnom Penh: United Nations Development Programme (UNDP).



អង្គការ ជីវិតនៅកម្ពុជា
THIS LIFE CAMBODIA
COMMUNITY RESEARCH AND CONSULTANCY

UNESCO
United Nations
Educational, Scientific and
Cultural Organization

uniTwin
UNESCO Chair in Comparative Education
The University of Hong Kong